សមាគមអាដហុក
ADHOC

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
Cambodian Human Rights and Development Association

ផ្ទះលេខ៣ ផ្លូវ១៥៨ ឧកញ៉ាទ្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ, № 3, St 158 Oukhna Troeung Kang, Boeng Raing, Daun Penh, Phnom Penh.
Tel: (+855-23) 218 653 / 210 518 / 990 544 P.O. Box: 1024 P.O, Box 20 at CCC , E-mail: info@adhoccambodia.org
Website: www.adhoccambodia.org, Facebook Page: www.facebook.com/adhoccam, Twitter: www.twitter.com/adhoccam

# ដំណឹងជ្រើសរើសបុគ្គលិក

**សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា** (**អាដហុក**) គឺជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ-អព្យាក្រឹតដែលមិនរកផលចំណេញ និងមិនស្ថិតក្រោមឥទ្ធិពលនយោបាយរបស់គណបក្សនយោបាយណាមួយ ហើយធ្វើការងារដើម្បីសង្គមមួយ ដែលគោរពសិទ្ធិមនុស្ស និងច្បាប់តាមរយៈការបង្កើនចំណេះដឹងផ្នែកសិទ្ធិមនុស្ស និងច្បាប់ដល់ប្រជាពលរដ្ឋធ្វើយ៉ាងណាឱ្យគាត់យល់អំពីសិទ្ធិមនុស្ស និងចេះការពារសិទ្ធិដោយខ្លួនឯង។ **សមាគមអាដហុក** ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៩១ ដែលមានការិយាល័យកណ្ដាលនៅទីស្នាក់ការភ្នំពេញ និងការិយាល័យខេត្ត-រាជធានី ចំនួន២១ ទៀត។

យោងតាមតម្រូវការជាចាំបាច់របស់ **សមាគម** នៅក្នុងពេលបច្ចុប្បន្ននេះ **សមាគមអាដហុក** សូមជូនដំណឹងដល់សាធារណៈជនទាំងអស់ឱ្យបានជ្រាបថា **សមាគម** ត្រូវការជ្រើសរើសបុគ្គលិកចំនួន**១រូប** ប្រចាំ**ការិយាល័យកណ្ដាលនៅភ្នំពេញ** ដែលមានតួនាទីជា **មេធាវី** ដើម្បីទទួលភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

## ភារកិច្ច និងការទទួលខុសត្រូវ ៖

- ការពារក្ដីករណីរំលោភសិទ្ធិស្ត្រី និងកុមារ (ករណីរំលោភសេពសន្ថវៈ ហិង្សាក្នុងគ្រួសារ និងករណីជួញដូរមនុស្ស)។
- ចូលរួមការការពារក្ដីរបស់កម្មវិធីសិទ្ធិមនុស្ស ដីធ្លី ធនធានធម្មជាតិ និងករណីផ្សេងៗក្នុងករណីចាំបាច់។
- ធ្វើរបាយការណ៍លទ្ធផលមេធាវីសំរាប់ប្រចាំខែ ៦ខែ (ឆមាស) និង ប្រចាំឆ្នាំ។
- តាមដានករណីដែលបានដាក់ពាក្យការពារក្ដីនៅតុលាការ។
- រៀបចំការគ្រប់គ្រង និងធ្វើផែនការករណីដែលត្រៀមការពារ និងបានដាក់ពាក្យការពារ។
- ផ្ដល់បទសម្ភាសន៍ទៅអ្នកសារព័ត៌មានក្នុងករណីចាំបាច់។
- ចុះជួបកូនក្ដីនៅមូលដ្ឋាន និងពន្ធនាគារ។
- ផ្ដល់ប្រឹក្សាយោបល់ផ្នែកច្បាប់ដល់បុគ្គលិកអាដហុក និងជនរងគ្រោះ (ករណីអ្នកអង្កេតជាប់រវល់) ។
- ចុះធ្វើការស៊ើបអង្កេត និងអន្តរាគមន៍តាមបណ្ដាខេត្ត/ក្រុង (ក្នុងករណីចាំបាច់)។
- ចូលជាវាគ្មិនក្នុងកម្មវិធីផ្សេងៗដូចជា: សិក្ខាសាលា វិទ្យុ ...។

- ជួយរៀបចំ ឬកែសម្រួលឯកសារផ្សេងៗដូចជាៈ សេចក្តីថ្លែងការណ៍ លិខិតអន្តរាគមន៍ ឯកសារមេរៀន... ដែលទាក់ទងនិងវិស័យច្បាប់ ។
- ចូលរួមស្រាវជ្រាវឯកសារច្បាប់ ដែលពាក់ព័ន្ធជាមួយការងារការពារក្តី និងការងារស៊ើបអង្កេត។
- រៀបចំបំពេញតារាងបំពេញការងារ (Time-sheet) ប្រចាំខែ។
- ចូលរួមប្រជុំនានា តាមការកំណត់របស់ផ្នែក។
- ចុះទំនាក់ទំនងការងារផ្នែកច្បាប់ជាមួយស្ថាប័នដទៃ។
- ធ្វើពាក្យបណ្តឹង ទទួលពាក្យបណ្តឹងរបស់អតិថិជន និងជូនអតិថិជនដាក់ពាក្យបណ្តឹងទៅស្ថាប័នពាក់ព័ន្ធក្នុងករណីចាំបាច់។
- បំពេញតួនាទី ភារកិច្ចបន្ថែមពីខាងលើ ប្រសិនបើមានករណីចាំបាច់ និងសំណើរពីប្រធានផ្នែកសិទ្ធិស្ត្រី និងកុមារ និងប្រធានផ្នែកសិទ្ធិមនុស្ស និងដីធ្លី។

## បេក្ខជន/បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិដូចតទៅ ៖

- អាយុចាប់ពី ២៥ឆ្នាំឡើង
- ត្រូវមានអាជ្ញាប័ណ្ណមេធាវីដែលមានសុពលភាព
- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រច្បាប់
- ធ្លាប់មានបទពិសោធន៍ធ្វើការងារជាមួយអង្គការសិទ្ធិមនុស្សជាតិ អន្តរជាតិ ២ឆ្នាំ ឡើងទៅ
- មានចំណេះដឹងផ្នែកសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ មានសេចក្តីក្លាហាន និងមានឆន្ទៈលះបង់ខ្ពស់
- មានបទពិសោធន៍ធ្វើការជាមួយតុលាការគ្រប់កម្រិតជាមួយអាជ្ញាធរថ្នាក់ជាតិ និងក្រោមជាតិទាក់ទងនឹងរឿងស្ត្រី កុមារ ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ
- មានវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់
- ស្ទាត់ជំនាញក្នុងការសរសេររបាយការណ៍
- បេក្ខជន បេក្ខនារី ត្រូវចេះភាសារខ្មែរស្ទាត់ជំនាញ (ទាំងសរសេរ និងអាន) និងមានចំណេះដឹងមូលដ្ឋានភាសាអង់គ្លេស
- មានចំណេះដឹងកុំព្យូទ័រជាមូលដ្ឋាន (Microsoft Word, Excel, PowerPoint, Internet&E-mail)

## ប្រាក់ខែ និងលក្ខខណ្ឌ ៖

សមាគមអាដហុកផ្តល់ប្រាក់ខែសរុបចំនួន ៨៥០ ដុល្លារ (មានបូក អត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភបន្ថែម)។ យើងកំពុងស្វែងរកបេក្ខជនដែលមានឆន្ទៈក្នុងការបំពេញតួនាទីនេះយ៉ាងតិចចាប់ពីមួយឆ្នាំឡើងទៅ។

បេក្ខជន/បេក្ខនារី ដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបមកការិយាល័យរដ្ឋបាល តាមអាសយដ្ឋានផ្ទះលេខ ៣ ផ្លូវ១៥៨ ឧកញ៉ាទ្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬតាមរយៈ៖ 023 218 653 / 086 407 666 និង អ៊ីម៉ែល recruitment@adhoccambodia.org ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ និងផុតកំណត់ទទួលពាក្យត្រឹម **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ៥ : 00 ល្ងាច**។

**សមាគមអាដហុក គឺអង្គការមិនមែនរដ្ឋាភិបាលដែលនិយោជិតទាំងអស់មានឱកាសស្មើគ្នា។ ស្ត្រីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជនជាតិភាគតិច និងជនពិការភាព ត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យស្នើសុំមុខតំណែងនេះ។**